**លិខិតបញ្ជាក់អំពើហិង្សាក្នុងគ្រួសារ**
**អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី**
**ការរំលោភផ្លូវភេទ ឬការឈ្លបចាប់**
**និងឯកសារ ដែលមានជម្រើស**

**ក្រសួងអភិវឌ្ឍលំនៅដ្ឋាន**
**និងទីក្រុងនៃសហរដ្ឋអាមេរិក**

OMB លេខអនុម័ត No. 2577-0286
ផុតកំណត់នៅថ្ងៃទី 30/06/2017

**គោលបំណងនៃសំណុំបែបបទ៖** ច្បាប់ស្តីពីអំពើហិង្សាលើស្ត្រី ("VAWA") ការពារបេក្ខជន អ្នកជួលលំនៅដ្ឋាន និងអ្នកចូលរួមកម្មវិធីនៅក្នុងកម្មវិធី HUD ជាក់លាក់ពីការបណ្តេញចេញ ការបដិសេធជំនួយលំនៅដ្ឋាន ឬការបញ្ឈប់ពីជំនួយលំនៅដ្ឋាន ដោយផ្អែកលើ មូលដ្ឋានការប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ប្រឆាំងពួកគេ។ បើទោះជាឈ្មោះនៃច្បាប់នេះ ជាការការពារច្បាប់ VAWA ដែលអាចប្រើចំពោះជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃ ការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ក៏ដោយ ក៏មិនគិតពីភេទ អត្តសញ្ញាណយេនឌ័រ ឬទំនោររួមភេទផងដែរ។

**ការប្រើប្រាស់សំណុំបែបបទដែលមានជម្រើសនេះ៖** ប្រសិនបើអ្នកកំពុងស្វែងរកការការពារដោយច្បាប់ VAWA ពីអ្នកផ្តល់សេវាកម្ម លំនៅដ្ឋានរបស់អ្នកនោះ អ្នកផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នកអាចផ្តល់ជូនអ្នកនូវសំណើជាលាយលក្ខណ៍អក្សរមួយច្បាប់ ដែលស្នើសុំ អ្នកដាក់បញ្ជូនឯកសារអំពីឧប្បត្តិហេតុ ឬឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។

ចំពោះឆ្លើយតបទៅនឹងសំណើនេះ អ្នកឬនរណាម្នាក់ក្នុងនាមតំណាងឱ្យអ្នក អាចបំពេញសំណុំបែបបទដែលមានជម្រើសនេះ និងដាក់បញ្ជូនសំណើទៅក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នក ឬអ្នកអាចដាក់បញ្ជូនឯកសារមួយប្រភេទនៃឯកសារភាគីទីបី ដូចខាងក្រោម៖

(1) ឯកសារដែលបានចុះហត្ថលេខាដោយអ្នក និងបុគ្គលិក ភ្នាក់ងារ ឬអ្នកស្ម័គ្រចិត្តនៃអ្នកផ្តល់សេវាកម្មជនរងគ្រោះ មេធាវី ឬអ្នកជំនាញវិជ្ជាជីវៈវេជ្ជសាស្ត្រ ឬអ្នកជំនាញសុខភាពផ្លូវចិត្ត (ដោយសហការណ៍, "អ្នកជំនាញវិជ្ជាជីវៈ") ពីអ្នកដែលអ្នកបានស្វែងរកជំនួយដែលទាក់ទងទៅនឹងអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ឬផលប៉ះពាល់ពីការរំលោភបំពាន។ ឯកសារនេះ ត្រូវបញ្ជាក់ ដែលស្ថិតក្រោមការពិន័យសម្បថ ដែលអ្នកជំនាញវិជ្ជាជីវៈជឿជាក់ថាឧប្បត្តិហេតុ ឬឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ដែលបានកើតឡើង និងបំពេញតាមនិយមន័យនៃ "អំពើហិង្សាក្នុងគ្រួសារ", "អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី", "ការរំលោភផ្លូវភេទ" ឬ "ការឈ្លបចាប់" នៅក្នុងបទប្បញ្ញត្តិ HUD នៅត្រង់ចំណុច 24 CFR 5,2003 ។

(2) កំណត់ត្រាទីភ្នាក់ងារអនុវត្តច្បាប់សហព័ន្ធ រដ្ឋ កុលសម្ព័ន្ធ ដែនដីអាណាខេត្ត ឬមូលដ្ឋាន, តុលាការ ឬទីភ្នាក់ងាររដ្ឋបាលមួយ; ឬ

(3) តាមការសម្រេចចិត្តរបស់អ្នកផ្តល់សេវាកម្មលំនៅដ្ឋាននោះ របាយការណ៍ ឬភស្តុតាងផ្សេងទៀតដែលបានផ្តល់ជូនដោយ បេក្ខជនដាក់ពាក្យសុំ ឬអ្នកជួលលំនៅដ្ឋាន។

**ការដាក់បញ្ជូនឯកសារ៖** រយៈពេលដាក់បញ្ជូនឯកសារគឺ 14 ថ្ងៃនៃថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលអ្នកទទួលបានសំណើជាលាយលក្ខណ៍ អក្សរពីអ្នកផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នក ដែលស្នើសុំអ្នកឱ្យផ្តល់ជូនឯកសារពាក់ព័ន្ធនឹងការកើតមានឡើងនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ អ្នកផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នកអាចពន្យាពេលដាក់បញ្ជូនឯកសារ ប៉ុន្តែមិនត្រូវបានទាមទារដូច្នេះឡើយ បើអ្នកស្នើសុំការពន្យាពេល។ ប្រសិនបើព័ត៌មានដែលបានស្នើសុំ មិនត្រូវបានទទួលក្នុងរយៈពេល 14 ថ្ងៃនៃថ្ងៃធ្វើការ នៅពេលអ្នកបានទទួលសំណើនេះ សម្រាប់ឯកសារ ឬការព្យាពេលណាមួយនៃកាលបរិច្ឆេទ ដែលបានផ្តល់ជូនដោយក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នកនោះ ក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នកមិនត្រូវការផ្តល់ជូនអ្នកនូវការការពារដោយច្បាប់ VAWA ណាមួយឡើយ។ ការចែកចាយ ឬការចេញសំណុំបែបបទនេះ មិនបម្រើជូនជាសំណើជា លាយលក្ខណ៍អក្សរសម្រាប់លិខិតបញ្ជាក់ឡើយ។

**ការរក្សារឿងសម្ងាត់៖** ព័ត៌មានទាំងអស់ដែលបានផ្តល់ជូនក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នក ដែលទាក់ទងនឹងឧប្បត្តិហេតុនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់ ត្រូវបានរក្សាទុកជាការសម្ងាត់ ហើយព័ត៌មានលម្អិតបែបនេះមិនត្រូវបានបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យដែលចែករំលែកណាមួយឡើយ។ បុគ្គលិកក្រុមហ៊ុនផ្តល់សេវាកម្មលំនៅដ្ឋានរបស់អ្នក មិនត្រូវមានសិទ្ធិចូលប្រើព័ត៌មានលម្អិតទាំងនេះឡើយ លុះត្រាតែផ្តល់ ឬបដិសេធការការពារដោយច្បាប់ VAWA ចំពោះអ្នក និងបុគ្គលិកមិនអាចបញ្ចេញឱ្យដឹងព័ត៌មាននេះ ទៅអង្គភាពណាមួយ ឬបុគ្គលណាម្នាក់ផ្សេងទៀតឡើយ លើកលែងតែមានកំណត់ទំហំនៃការបញ្ចេញឱ្យដឹងព័ត៌មាននោះត្រូវបាន៖ (i) យល់ព្រមដោយអ្នក ដោយសរសេរជាលាយលក្ខណ៍អក្សរចំពោះការបញ្ចេញឱ្យដឹងព័ត៌មានដែលមានពេលវេលាកំណត់ពេលវេលា; (ii) ទាមទារសម្រាប់ការប្រើប្រាស់នៅក្នុងដំណើរការបណ្តេញចេញ
ឬសវនាការដែលទាក់ទងនឹងការបញ្ចប់ជំនួយ; ឬ (iii) តាមរបៀបផ្សេងទៀត ត្រូវបានទាមទារដោយច្បាប់ជាធរមាន។

**ត្រូវបានបំពេញដោយជនរងគ្រោះ ឬក្នុងនាមជាជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួបបុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់**

**1. កាលបរិច្ឆេទសំណើជាលាយលក្ខណ៍អក្សរត្រូវបានទទួលដោយជនរងគ្រោះ៖** ______________________________

**2. ឈ្មោះជនរងគ្រោះ៖** ______________________________

**3. ឈ្មោះរបស់អ្នក (បើមានខុសគ្នាពីជនរងគ្រោះ)៖** ______________________________

**4. ឈ្មោះសមាជិកគ្រួសារផ្សេងទៀត ដែលបានចុះបញ្ជីឈ្មោះក្នុងកិច្ចសន្យាជួល៖** ______________________________

______________________________

**5. លំនៅដ្ឋានជនរងគ្រោះ៖** ______________________________

**6. ឈ្មោះជនល្មើសដែលបានចោទប្រកាន់ (បើស្គាល់ និងអាចបង្ហាញដោយសុវត្ថិភាព)៖** ______________________________

______________________________

**7. ទំនាក់ទំនងរបស់ជនល្មើសដែលបានចោទប្រកាន់ចំពោះជនរងគ្រោះ៖** ______________________________

**8. កាលបរិច្ឆេទ និងម៉ោងកើតហេតុ (បើដឹង):** ______________________________

______________________________

**10. ទីកន្លែងកើតហេតុ៖** ______________________________

តាមពាក្យសម្ដីផ្ទាល់ខ្លួនរបស់អ្នក សូមរៀបរាប់ដោយសង្ខេបអំពីឧប្បត្តិហេតុនេះ៖

______________________________

______________________________

______________________________

______________________________

សូមបញ្ជាក់ថាព័ត៌មានដែលបានផ្ដល់ជូនក្នុងសំណុំបែបបទនេះ គឺជាការពិត និងត្រឹមត្រូវ តាមចំណេះដឹង និងការចងចាំរបស់ខ្ញុំដ៏ល្អបំផុត ហើយថាបុគ្គលដែលមានឈ្មោះខាងលើនៅត្រង់ចំណុច 2 ឬជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួប បុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ ខ្ញុំទទួលស្គាល់ថាការដាក់ជូនព័ត៌មានមិនពិតអាចបង្កឱ្យមានបញ្ហាភាពមានសិទ្ធិស្របច្បាប់ចំពោះកម្មវិធី និងអាចជាមូលដ្ឋានចំពោះការបដិសេធការទទួលស្គាល់ ការបញ្ចប់ផ្ដល់ជំនួយ ឬការបណ្ដេញចេញ។

ហត្ថលេខា ______________________ បានចុះហត្ថលេខា (កាលបរិច្ឆេទ) ______________________

**ការទទួលបន្ទុករបាយការណ៍សាធារណៈ៖** បន្ទុករបាយការណ៍ជាសាធារណៈចំពោះការប្រមូលផ្តុំព័ត៌មាននេះ ត្រូវបានប៉ាន់ប្រមាណ
រយៈពេលជាមធ្យម 1 ម៉ោងក្នុងការឆ្លើយតបមួយ។ ការណ៍នេះ រួមបញ្ចូលទាំងពេលវេលាសម្រាប់ការប្រមូល ការពិនិត្យឡើងវិញ និងការរាយការណ៍ទិន្នន័យ។ ព័ត៌មានដែលផ្ដល់ជូននេះ ត្រូវបានប្រើដោយក្រុមហ៊ុនផ្ដល់សេវាកម្មលំនៅដ្ឋាន ដើម្បីស្នើសុំលិខិតបញ្ជាក់ដែលបេក្ខជន ឬអ្នកជួលលំនៅដ្ឋាន គឺជាជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ អំពើហិង្សានៃការណាត់ជួប បុរសនិងស្ត្រី ការរំលោភផ្លូវភេទ ឬការឈ្លបចាប់។ ព័ត៌មាននេះ ត្រូវបានកំណត់ថាជាតម្រូវការសម្ងាត់នៃច្បាប់ VAWA។ ទីភ្នាក់ងារនេះ មិនអាចប្រមូលព័ត៌មាននេះ ហើយអ្នកមិនត្រូវបានទាមទារឱ្យបំពេញសំណុំបែបបទនេះឡើយ លុះត្រាតែបច្ចុប្បន្នព័ត៌មានបង្ហាញនៅការិយាល័យគ្រប់គ្រង និងលេខគ្រប់គ្រងថវិកាដែលត្រឹមត្រូវ។